**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

លេខ : ......១៤៤៥....ឯក..រអា...... ថ្ងៃច័ន្ទ ១៤កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមិថុនា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## ការស្នើសុំអាជ្ញាបណ្ណសម្រាប់ការបង្កើតនិងធ្វើអាជីវកម្មមជ្ឈមណ្ឌលទិន្នន័យ ( Data Center )

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ (**ក.ប.ទ.**) សូមជម្រាបជូន **លោក លោកស្រី ជាម្ចាស់ ឬតំណាងក្រុមហ៊ុន សហគ្រាស និងសាខាក្រុមហ៊ុនបរទេស** ទាំងអស់ជ្រាបថា រាល់ក្រុមហ៊ុនដែលមានបំណងបង្កើតនិងធ្វើអាជីវកម្មមជ្ឈមណ្ឌលទិន្នន័យជូនអតិថិជន ដែលផ្តល់សេវាកម្មមានជាអាទិ៍ ១-ការរក្សាទុកទិន្នន័យ ការបង្ហោះគេហទំព័រ និង/ឬ អ៊ីម៉ែល ២-ការជួលទីតាំង និង/ឬម៉ាស៊ីនមេ ៣-ការថែទាំសុសវែរ និង/ឬគ្រឿងសម្ភារៈបរិក្ខារកុំព្យូទ័ររបស់អតិថិជនដែលដាក់ឱ្យដំណើរការនៅក្នុងមជ្ឈមណ្ឌលទិន្នន័យ ៤-ការការពារនិងរក្សាសុវត្ថិភាពទិន្នន័យនៅក្នុងមជ្ឈមណ្ឌលទិន្នន័យ ៥-ការផ្តល់សេវាបច្ចេកវិទ្យាក្លោដ រួមមាន សេវាហេដ្ឋារចនាសម្ព័ន្ធ ( Infrastructure as a Service – IaaS ) សេវាសម្រាប់ការអភិវឌ្ឍនិងដំណើរការសុសវែរ ( Platform as a Service – PaaS ) និងសេវាសម្រាប់ការប្រើប្រាស់សុសវែរ ( Software as a Service – SaaS ) ត្រូវស្នើសុំអាជ្ញាបណ្ណការបង្កើតនិងធ្វើអាជីវកម្មមជ្ឈមណ្ឌលទិន្នន័យពី **ក.ប.ទ.**។

កន្លងមក **ក.ប.ទ.** តែងតែផ្សព្វផ្សាយជាប្រចាំដល់ក្រុមហ៊ុន សហគ្រាស និងសាខាក្រុមហ៊ុនបរទេស ដែលកំពុងប្រតិបត្តិការផ្តល់សេវាកម្មលើមជ្ឈមណ្ឌលទិន្នន័យ ដោយពុំមានការអនុញ្ញាត និងមានបំណងបង្កើតនិងធ្វើអាជីវកម្មមជ្ឈមណ្ឌលទិន្នន័យ ឱ្យមកដាក់ពាក្យស្នើសុំការអនុញ្ញាតបំពេញប្រតិបត្តិការពី **ក.ប.ទ.** ស្របតាមបទប្បញ្ញត្តិជាធរមាន។ យោងតាមមាត្រា៥ នៃអនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់ការអនុញ្ញាតបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន បានចែងថា “**គ្មានបុគ្គលណាអាចបំពេញប្រតិបត្តិការលើវិស័យបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាននៅក្នុងព្រះរាជាណាចក្រកម្ពុជាបានទេ លើកលែងតែបុគ្គលនោះបានទទួលលិខិតអនុញ្ញាត វិញ្ញាបនបត្រ ឬអាជ្ញាបណ្ណ ពី ក.ប.ទ.**”។

ក្នុងន័យនេះ **ក.ប.ទ.** សូមអំពាវនាវសារជាថ្មីដល់លោក លោកស្រី ជាម្ចាស់ ឬតំណាងក្រុមហ៊ុន សហគ្រាស និងសាខាក្រុមហ៊ុនបរទេសទាំងអស់ ដែលកំពុងធ្វើប្រតិបត្តិការដោយពុំមានការអនុញ្ញាត ឬមានបំណងបង្កើតនិងធ្វើអាជីវកម្មមជ្ឈមណ្ឌលទិន្នន័យ សូមមកដាក់ពាក្យស្នើសុំការអនុញ្ញាតពី **ក.ប.ទ.** ស្របតាមបទប្បញ្ញត្តិជាធរមាន ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ។ ចំពោះក្រុមហ៊ុន សហគ្រាស និងសាខាក្រុមហ៊ុនបរទេសណាដែលធ្វើប្រតិបត្តិការផ្តល់សេវាកម្មលើមជ្ឈមណ្ឌលទិន្នន័យដោយពុំមានការអនុញ្ញាត នឹងត្រូវទទួលរងពិន័យអន្តរការណ៍ ឬបញ្ឈប់សកម្មភាពអាជីវកម្ម ឬប្រឈមនឹងវិធានការនានាស្របតាមបទប្បញ្ញត្តិជាធរមាន។ ចំពោះព័ត៌មានបន្ថែម លោក លោកស្រី អាចសាកសួរនៅរៀងរាល់ម៉ោងធ្វើការតាមរយៈទូរសព្ទលេខ ០២៣ ៧២៣ ០៨៣។

អាស្រ័យហេតុនេះ សូម លោក លោកស្រី ជាម្ចាស់ ឬតំណាងក្រុមហ៊ុន សហគ្រាស និងសាខាក្រុមហ៊ុនបរទេស ជ្រាបជាព័ត៌មាននិងចូលរួមអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។